# ផលអាក្រក់នៃការកំណត់ស្លាកសិស្ស

# The Dangers of Student Labeling

## ឯកសារបំប៉នកម្មវិធីសាលារៀនជំនាន់ថ្មី

ក្រសួងអប់រំ យុវជន និងកីឡា

**ឯកសារសិក្ខាកាម**

# ឯកសារចែក

- ឯកសារចែក ១: ការបង្រៀនក្រុមសិស្សដែលមានសមត្ថភាពមធ្យមនៅក្នុងថ្នាក់រៀន
- ឯកសារចែក ២: ករណីសិក្សា: ការកំណត់ស្លាកសិស្ស និងការរំពឹងទុករបស់គ្រូបង្រៀន
- ឯកសារចែក ៣: សេចក្តីសង្ខេបពាក្យ និងបញ្ញត្តិសំខាន់ៗនៃការរៀបក្រុមសិស្សតាមកម្រិតសមត្ថភាព
- ឯកសារចែក ៤: គុណសម្បត្តិ និងគុណវិបត្តិនៃការរៀបក្រុមសិស្សតាមកម្រិតសមត្ថភាព
- ឯកសារចែក ៥: លំហាត់អំពីការកំណត់ស្លាកសិស្ស
- ឯកសារចែក ៦: ទ្រឹស្តីពហុបញ្ញា
- ឯកសារចែក ៧: ការកាត់បន្ថយការអនុវត្តបែបកំណត់ស្លាកសិស្សក្នុងប្រទេសកម្ពុជា

## ឯកសារចែក ១: **ការបង្រៀនក្រុមសិស្សដែលមានសមត្ថភាពមធ្យម នៅក្នុងថ្នាក់រៀន**

- ជាធម្មតាសិស្សត្រូវបានបែងចែកជាបីក្រុមនៅក្នុងថ្នាក់រៀនជាច្រើន:
  - សិស្សមានសមត្ថភាព**ខ្ពស់**
  - សិស្សមានសមត្ថភាព**មធ្យម** (សមត្ថភាពកណ្តាល)
  - សិស្សមានសមត្ថភាព**ទាប**
- ដូច្នោះនៅក្នុងថ្នាក់រៀនមានទិដ្ឋភាពដូចក្នុងរូបខាងក្រោម:




- គ្រូបង្រៀនជាទូទៅរៀបចំការបង្រៀនឆ្លើយតបទៅនឹងតម្រូវការក្រុមសិស្សដែលមានសមត្ថភាពមធ្យម(កណ្តាល) ដោយសារក្រុមនេះមានគ្នាច្រើនជាងគេ ។
- ប៉ុន្តែ តើមានអ្វីកើតឡើងចំពោះក្រុមសិស្សដែលមានសមត្ថភាពកម្រិតទាប ឬកម្រិតខ្ពស់ បើសិនគ្រូបង្រៀនយកចិត្តទុកដាក់តែក្រុមសិស្សមានសមត្ថភាពមធ្យម ?
  - ចម្លើយ: សិស្សមានសមត្ថភាពខ្ពស់តែងតែធុញទ្រាន់នឹងមេរៀន ហើយសិស្សដែលមានសមត្ថភាពទាបត្រូវបានទុកចោល មិនសូវបានយកចិត្តទុកដាក់ ។
- ដើម្បីការពារបញ្ហានេះកើតឡើង អ្នកអប់រំមួយចំនួនបានស្នើការបង្រៀនដោយរៀបចំជាក្រុមតាមកម្រិតសមត្ថភាព ហើយរៀបចំការង្រៀនស្របទៅតាមតម្រូវការទាំងនោះ ។
- ទោះបីជាយ៉ាងណាក៏ដោយវិធីសាស្រ្តនេះក៏មានហានិភ័យផងដែរ ។

# ឯកសារចែក ២: ករណីសិក្សា: ការកំណត់ស្លាកសិស្ស និងការរំពឹងទុករបស់គ្រូបង្រៀន

*សេចក្តីណែនាំ: សូមអានករណីសិក្សា រួចឆ្លើយសំណួរខាងក្រោម:*

*អ្នកស្រាវជ្រាវមួយក្រុមបានធ្វើពិសោធន៍ដោយឱ្យសិស្សទាំងអស់ក្នុងថ្នាក់ធ្វើតេស្ត ។ ពួកគេបានធ្វើចំណាត់ថ្នាក់ពិន្ទុសិស្សពីខ្ពស់មកទាប ។ បន្ទាប់មកពួកគេបានបញ្ច្រាសសិស្សទាំងនោះដោយសិស្សដែលបានពិន្ទុខ្ពស់ត្រូវទទួលពិន្ទុទាប ហើយសិស្សដែលទទួលបានពិន្ទុទាបត្រូវទទួលបានពិន្ទុខ្ពស់វិញ ។ បន្ទាប់មកពួកគេបានយកបញ្ជីសិស្សនិងពិន្ទុដែលបានបញ្ច្រាសទៅបង្ហាញគ្រូបង្រៀនដែលមកថ្មីដែលត្រូវទៅបង្រៀនសិស្សទាំងនេះ ។*

*គួរឱ្យភ្ញាក់ផ្អើល អ្នកស្រាវជ្រាវរកឃើញថាសិស្សដែលគ្រូបង្រៀនបានគិតថាជាសិស្សដែលទទួលបានពិន្ទុខ្ពស់ ពិតជាទទួលបានចំណាត់ថ្នាក់ខ្ពស់ ចំណែកឯសិស្សដែលគ្រូបានគិតថាទទួលបានពិន្ទុទាបពិតជាទទួលបានចំណាត់ថ្នាក់ទាប បើទោះបីជាពួកគេធ្លាប់ជាសិស្សពូកែពីមុនក៏ដោយ ។*

## *សំណួរពិភាក្សា*

1. ហេតុអ្វីបានជាសិស្សដែលមានសមត្ថភាពខ្ពស់ពិតប្រាកដបានទទួលពិន្ទុចំណាត់ថ្នាក់ទាប ហើយសិស្សដែលមានសមត្ថភាពទាបទទួលបានចំណាត់ថ្នាក់ពិន្ទុខ្ពស់?
2. តើលទ្ធផលនេះចង់បង្ហាញអ្វីអំពីអំណាចនៃការរំពឹងទុករបស់គ្រូបង្រៀន

# ឯកសារចែក ៣: សេចក្តីសង្ខេបពាក្យ និងបញ្ញត្តិសំខាន់ៗនៃការរៀបក្រុមសិស្សតាមកម្រិតសមត្ថភាព

*ពាក្យ ដែលសង្ខេបខាងក្រោមជួយឱ្យសិក្ខាកាមយល់ដឹងកាន់តែប្រសើរឡើងពីបញ្ញត្តិសំខាន់ៗទាក់ទងនឹងការអនុវត្តការរៀបចំក្រុមសិស្សតាមកម្រិតសមត្ថភាព ។*

| ពាក្យ | សេចក្តីពន្យល់ |
|---|---|
| *ការបង្រៀនសិស្សមានសមត្ថភាពមធ្យម (កណ្តាល)*   | ការអនុវត្តការបង្រៀនដែលឆ្លើយតបនឹងតម្រូវការតែក្រុមសិស្សភាគច្រើននៅក្នុងថ្នាក់រៀន ដោយផាត់ចោលក្រុមសិស្សដែលមានសមត្ថភាពទាប និងខ្ពស់ ។ |
| *ការមាក់ងាយ*  | សញ្ញាមួយនៃភាពអាម៉ាស់ ឬភាពខ្មាសអៀនដែលកើតចេញពីលក្ខណៈពិសេសណាមួយប្រព្រឹត្តទៅលើសិស្សជាពិសេសដោយសារពួកគេទទួលសមិទ្ធផលការសិក្សាទាប ។ |
| *ការដាក់ស្លាកសិស្ស*  | ការអនុវត្តដែលចាត់សិស្សចូលទៅក្នុងប្រភេទឬក្រុមជាក់លាក់ណាមួយដោយមានលក្ខណៈ "រឹតត្បិត" ឬ "មិនត្រឹមត្រូវ" ឬ សំដៅលក្ខណៈទាំងពីរនេះរួមគ្នា ។ |
| *ទំនាយដោយខ្លួនឯង*  | **ទំនាយដោយខ្លួនឯង**គឺជាការទស្សន៍ទាយមួយដោយផ្ទាល់ឬដោយប្រយោលថាខ្លួនឯងនឹងក្លាយជាការពិតដោយសារតែការឆ្លើយជាវិជ្ជមានរវាងជំនឿនិងអាកប្បកិរិយាមួយ។ |
| *ការរំពឹងទុករបស់គ្រូបង្រៀន*  | ជំនឿរបស់គ្រូបង្រៀនអំពីអាកប្បកិរិយារបស់សិស្សដែលជំនឿនោះនឹងរួមចំណែកដល់ការសម្រេចបាននៃអាកប្បកិរិយានោះ។ ការរំពឹងទុកអាចមានលក្ខណៈអវិជ្ជមានឬវិជ្ជមាន។ |

# ឯកសារចែក ៩: គុណសម្បត្តិ និងគុណវិបត្តិនៃការរៀបក្រុមសិស្សតាមកម្រិតសមត្ថភាព[1]



| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| 1. **សិស្សអាចរៀនទៅតាមដំណើរឬល្បឿនរបស់ខ្លួន:** សម្ពាធទៅលើសិស្សក្នុងពេលបង្រៀនប្រធានបទអ្វីមួយត្រូវបានបន្ថយឱ្យនៅតិចនៅពេលដែលសិស្សត្រូវបានដាក់ជាក្រុមរួមគ្នាតាមកម្រិតបំណិនឬសមត្ថភាព ។ សិស្សដែលយល់ពីបញ្ញត្តិអាចបន្តល្បឿនរបស់ខ្លួនទៅមុខទៀតនៅពេលដែលពួកគេបានឈានដល់ការយល់ដឹងសមស្របមួយ។ ដូចគ្នានេះដែរសិស្សដែលមានរបៀបរៀនដែលត្រូវការពេលវេលាយូរដើម្បីយល់ពីគោលគំនិតអ្វីមួយក៏មិនត្រូវបានផាត់ចោលដោយគ្រាន់តែសំអាងថាសិស្សក្នុងថ្នាក់ទាំងមូលត្រូវបន្តសិក្សាទៅមុខទៀត ។ ពួកគេគ្រាន់តែត្រូវការពេលវេលាទៅតាមតម្រូវការនិងបន្តវឌ្ឍនភាពរបស់ខ្លួនតាមពេលវេលាសមស្រប ។ | 1. **លទ្ធភាពនៃការមិនរាប់បញ្ចូលនិងការថប់បារម្ភ:** លទ្ធភាពដែលអាចកើតឡើងគឺថាសិស្សមួយចំនួននឹងជួបប្រទះភាពមិនស្រួលក្នុងអារម្មណ៍នៅពេលដាក់ចូលទៅក្នុងក្រុមមួយដែលត្រូវបានចាត់ទុកថាជាក្រុមកម្រិតទាបជាងឬខ្ពស់ជាងគេ ។ ការរៀបក្រុមក៏បង្ហាញឱ្យឃើញអំពីភាពខុសគ្នានៃសមត្ថភាពចំណេះដឹងក្នុងចំណោមសិស្សនិងអាចនាំឱ្យមានអារម្មណ៍ឯកោនិងការបំបែកពីក្រុមធំ ។ |

[1] Adapted from: https://uoitonlinetech.wordpress.com/2012/06/11/pros-and-cons-of-grouping-students-by-ability/

2. **គ្រូបង្រៀនអាចធ្វើការជិតស្និទ្ធជាមួយសិស្សដែលត្រូវការជំនួយច្រើន:** នៅពេលសិស្សត្រូវបានរៀបជាក្រុមតាមកម្រិតសមត្ថភាព នោះតម្រូវឱ្យមានការងារសហការគ្នាពីព្រោះបរិយាកាសសិក្សាបែបនេះគឺពឹងផ្អែកយ៉ាងខ្លាំងលើការងារជាក្រុម។ ខណៈពេលដែលសិស្សធ្វើការក្រុមរួមគ្នានិងរៀនសូត្រពីគ្នា គ្រូបង្រៀនអាចប្រើពេលវេលាជាមួយសិស្សផ្សេងទៀតដែលត្រូវការយកចិត្តទុកដាក់ជួយមួយទល់មួយ។

2. **សិស្សដែលស្ថិតក្នុងក្រុមកម្រិតសមត្ថភាពទាបជាងគេអាចនឹងរៀនតាមតែកម្រិតនោះរហូត:** បើសិនគេរៀបសិស្សទៅក្នុងក្រុមមួយដែលការសិក្សាមានល្បឿនយឺតជាង ហើយបញ្ញត្តិដែលត្រូវសិក្សាត្រូវចំណាយពេលយូ នោះធ្វើឱ្យសិស្សខ្លះអាចធ្វើការតាមតែកម្រិតក្រុមនោះ ទោះបីជាពួកគេមានសមត្ថភាពច្រើនជាងក៏ដោយ ។ ការរៀបចំបែបនេះបង្កើតជាលទ្ធភាពមួយនៃការចាត់សិស្សទៅតាមកម្រិតប្រភេទនៃភាព "ឆ្លាត" ហើយសិស្សខ្លះនឹងធ្វើការទៅតាមកម្រិតក្រុមដែលខ្លួនស្ថិតនៅ ។ ពេលខ្លះ ទំនោរបែបនេះគេហៅថាជាទំនាយដែលកំណត់ដោយខ្លួនឯង។

# ឯកសារចែក ៥: លំហាត់អំពីការកំណត់ស្លាកសិស្ស

*សេចក្ដីណែនាំ: សូមត្រួតពិនិត្យសេចក្ដីថ្លែងខាងក្រោម រួចកំណត់ថាតើ ត្រូវ ឬ ខុស ។*

| *សេចក្ដីថ្លែង* | *ត្រូវ ឬ ខុស* |
|---|---|
| 1. ក្នុងពេលបង្រៀនទៅកាន់ថ្នាក់ទាំងមូល គ្រូបង្រៀនជាធម្មតាបង្រៀនសិស្សដែលមានសមត្ថភាពកម្រិតមធ្យម (កណ្ដាល) ហើយទុកចោលសិស្សដែលមានសមត្ថភាពខ្ពស់ជាង ឬ ទាបជាង ។ | ________ |
| 2. វិធីបង្រៀនដែលល្អបំផុតគឺរៀបសិស្សជាក្រុមជាអចិន្ត្រៃយ៍ទៅតាមកម្រិតសមត្ថភាព ។ | ________ |
| 3. នៅពេលយើងរៀបសិស្សទៅក្នុងក្រុមដែលមានកម្រិតសមត្ថភាពទាបជាងគេ សិស្សទាំងនោះបានដឹងនិងទទួលយកការរៀបចំបែបនេះ ដូច្នេះវាមិនមានបញ្ហាអ្វីឡើយដែលយើងនិយាយជាមួយពួកគេដោយបើកចំហរ ។ | ________ |
| 4. វាមិនមានបញ្ហាអ្វីទេដែលយើងនិយាយដោយចំហរថា "សិស្សរៀនខ្សោយ" "សិស្សរៀនយឺត" ឬ "សិស្សរៀនមិនទាន់គេ" ។ | ________ |
| 5. ទោះបីជាមានហានិភ័យទាក់ទងនឹងការរៀបសិស្សជាក្រុមតាមកម្រិតសមត្ថភាពក៏ដោយ វាក៏មានគុណសម្បត្តិច្រើនផងដែរ បើសិនជាយើងចេះគ្រប់គ្រងហានិភ័យទាំងនោះឱ្យបានត្រឹមត្រូវ ។ | ________ |
| 6. ហានិភ័យមួយក្នុងចំណោមហានិភ័យផ្សេងទៀតទាក់ទងនឹងការរៀបសិស្សជាក្រុមតាមកម្រិតសមត្ថភាពនោះគឺវាអាចនាំទៅរក*ទំនាយដែលកំណត់ដោយខ្លួនឯង* ។ | ________ |

## ឯកសារចែក ៦: ទ្រឹស្តីពហុបញ្ញា

ទ្រឹស្តីពហុបញ្ញាបង្កើតដោយលោក *Howard Gardner* ក្នុងទសវត្សឆ្នាំ ១៩៨០។ វាជាគំនិតមួយដែលបានបង្ហាញថាមនុស្សយើងមានបញ្ញាខុសៗគ្នា ហើយប្រព័ន្ធអប់រំបង្ហាញនូវភាពលំអៀងទៅលើបញ្ញាមួយចំនួន (ឧ.បញ្ញាផ្នែកភាសា បញ្ញាផ្នែកគណិតវិទ្យា) ហើយមិនយកចិត្តទុកដាក់ចំពោះប្រភេទបញ្ញាជាច្រើនទៀត។



# សកម្មភាពពិភាក្សាក្រុម




សេចក្តីណែនាំ:សូមគិតអំពីពហុបញ្ញានៅក្នុងដ្យាក្រាមខាងលើ រួចព្យាយាមកំណត់ប្រភេទការងារជាក់លាក់ដែលប្រើប្រាស់បញ្ញាទាំងនេះ។ចូរបំពេញតារាងខាងក្រោមដើម្បីកត់ត្រាគំនិតរបស់អ្នក។

| ប្រភេទបញ្ញា | ប្រភេទការងារ |
|---|---|
| បញ្ញាផ្នែកទំនាក់ទំនងបុគ្គល ឬការស្វែងយល់ពីចិត្តអ្នកដទៃ | •<br>•<br>• |
| បញ្ញាក្នុងការស្មានពីទ្រង់ទ្រាយក្នុងលំហ | •<br>•<br>• |
| បញ្ញាផ្នែកតន្ត្រី | •<br>•<br>• |
| បញ្ញាផ្នែកធម្មជាតិ | •<br>•<br>• |
| បញ្ញាផ្នែករាងកាយ និងចលនា | •<br>•<br>• |
| បញ្ញាផ្នែកភាសា | •<br>•<br>• |
| បញ្ញាផ្នែកតក្កវិទ្យា និងគណិតវិទ្យា | •<br>•<br>• |
| បញ្ញាក្នុងការស្គាល់ខ្លួនឯង | •<br>•<br>• |

# ឯកសារចែក ៧: **ការកាត់បន្ថយការអនុវត្តបែបកំណត់ស្លាកសិស្សក្នុងប្រទេសកម្ពុជា**

***សេចក្តីណែនាំ៖*** *សិក្ខាកាមអង្គុយជាក្រុមប្រមាណ៦ទៅ៧នាក់។ សូមពិភាក្សាគ្នាដើម្បីបំពេញតារាងខាងក្រោមដោយកំណត់ការអនុវត្តទូទៅចំនួន៣ក្នុងប្រទេសកម្ពុជាដែលបានកំពុងលើកស្ទួយការកំណត់ស្លាកសិស្ស។ នៅពេលបំពេញតារាង សូមធានាថា (១) កំណត់បានការអនុវត្តនិងរបៀបដែលវាជះឥទ្ធិលទៅលើសិស្ស (២) ប្រាប់ថាវាកើតឡើងនៅកម្រិតបឋមសិក្សា មធ្យមសិក្សា ឬទាំងពីរ រួចហើយ (៣) បង្ហាញពីរបៀបផ្លាស់ប្តូរការអនុវត្តនេះ (សូមផ្តល់គំនិតស្នើឡើងឱ្យបានច្រើន) ដែលអាចជួយកាត់បន្ថយឥទ្ធិពលរបស់វាទៅលើសិស្ស។ សូមមើលគម្រូឧទាហរណ៍*

| **ការអនុវត្តបែបកំណត់ស្លាកសិស្ស** | **កើតមាននៅ (✓)** | | **ដំណោះស្រាយដែលអាចយកទៅអនុវត្ត** |
|---|---|---|---|
| | **បឋមសិក្សា** | **មធ្យមសិក្សា** | |
| ឧទាហរណ៍:<br>**ពិធីផ្តល់រង្វាន់សិស្សពូកែ**<br>• ការអនុវត្តនេះធ្វើឱ្យសិស្សដែលមានដុងតិចពីកំណើតធ្វើការឆ្លុះបញ្ចាំងលើកង្វះសមត្ថភាពរបស់ខ្លួន<br>• វាក៏អាចបង្កើតជាអារម្មណ៍អស់សង្ឃឹម ឬរហូតដល់ការតូចចិត្ត | ✓ | ✓ | • **ដំណោះស្រាយទី១**: បំបាត់ការបង្កើតកម្មវិធីនេះ<br>• **ដំណោះស្រាយទី២**: សូមឱ្យតែសិស្សដែលត្រូវទទួលរង្វាន់ចូលរួមតែប៉ុណ្ណោះ ដោយមិនអញ្ជើញគ្រប់គ្នាក្នុងសាលារៀន។<br>• **ដំណោះស្រាយទី៣**: កំណត់ពីប្រភេទបញ្ហាផ្សេងៗទៀតរបស់សិស្ស ដូច្នោះគ្រប់គ្នានឹងទទួលបានប្រភេទរង្វាន់ណាមួយដូចៗគ្នា |
| **ការអនុវត្តទី១**: | | | |

| ការអនុវត្តបែបកំណត់ស្លាកសិស្ស | កើតមាននៅ (✓) | | ដំណោះស្រាយដែលអាចយកទៅអនុវត្ត |
|---|---|---|---|
| | បឋមសិក្សា | មធ្យមសិក្សា | |
| | | | |
| ការអនុវត្តទី២: | | | |

| ការអនុវត្តបែបកំណត់ស្លាកសិស្ស | កើតមាននៅ (✓) | | ដំណោះស្រាយដែលអាចយកទៅអនុវត្ត |
|---|---|---|---|
| | បឋមសិក្សា | មធ្យមសិក្សា | |
| | | | |
| ការអនុវត្តទី៣: | | | |